# រឿងហេតុកើតមាននៅភូមិសំឡូត

នៅថ្ងៃទី ៨ មីនា ឆ្នាំ ១៩៦៥, កងឯកភាព នៃកងទ័ពជើងទឹក អាមេរិកាំង បានចុះពីនាវា នៅ ខេត្ត ដាណង ក្នុងប្រទេសវៀតណាមខាងត្បូង។ លោក Lyndon Baines Johnson, ប្រធានាធិបតី សហរដ្ឋអាមេរិក, បានឲបេសកកម្មយ៉ាងច្បាស់លាស់ ដល់កងឯកភាពនេះ គឺះ សង្គ្រោះ សេរីភាព ប្រជាជន នៃយុវសាធារណរដ្ឋ វៀតណាមខាងត្បូង ដែលកំពុងមានការគំរាម កំហែងពីសំណាក់ពួកកុម្មុយនិស្តយួន។ ចំពោះ លោក ប្រធានាធិបតី អាមេរិកាំង ហានិភ័យ ក្រហម នេះ ជាគ្រោះថ្នាក់ ដល់បណ្តាប្រទេសអាស៊ីទៅថ្ងៃមុខទៀតជាពុំខាន មានជា ភស្តុតាង ជាក់លាក់ ដូចយ៉ាង ប្រទេសចិន បានក្លាយជាប្រទេស កុម្មុយនិស្ត ក្នុងឆ្នាំ ១៩៤៩, កងទ័ពកូរ៉េ ខាងជើង បានវាយសំរុកចូលកូរ៉េខាងត្បូង ក្នុងឆ្នាំ ១៩៥០, នៅក្នុងកំឡុងឆ្នាំ១៩៤០ និង ១៩៥០ មានកើត ការបះបោល នៃពួកកុម្មុយនិស្ត នៅប្រទេស ហ្វីលីពីន និង ម៉ាឡេស៊ី, ក្នុង ឆ្នាំ ១៩៥៤ ពួកវៀតមិញបានទទួលជ័យជំនះលើ កងកម្លាំងបេសនកម្មបារាំង នៅ បៀ បៀន ភូ, ហើយចាប់ពីឆ្នាំ១៩៦០ កងកម្លាំងយួនកុម្មុយនិស្ត មកពី វៀតណាមខាងជើង ជ្រៀត ចូល កាន់តែច្រើនឡើងៗ មកក្នុង វៀតណាមខាងត្បូង។ ដូច្នេះ ត្រូវចាំបាច់ ធ្វើផ្អុក ទុបជន់ លិច នៃទាហ៊ាន របស់ លោក ហូ ជីមិញ ជ្រាបចូលក្នុង វៀតណាមខាងត្បូង។ បេសកកម្ម កង ទ័ពជើងទឹកអាមេរិកាំង នៅវៀតណាមខាងត្បូង គឺជាចម្លើយនឹង ហានិភ័យក្រហម នេះឯង។ ដូច្នេះ លោក ឧត្តមសេនីយ Westmorland, អគ្គមេបញ្ជាការកងទ័ពប្រតិបត្តិការ អាមេរិកាំង នៅ វៀតណាមខាងត្បូង, មានបេសកកម្ម រៀបចំយុទ្ធសាស្ត្រ ដើម្បីទប់ទល់ ឲបានខ្លាំងក្លា នឹង ទ័ពព្រៃកុម្មុយនិស្ត។ យុទ្ធសាស្ត្រយោធានេះមានឈ្មោះថា «ស្វែងរក និងកំទេចចោល» ដែលជាយុទ្ធសាស្ត្រ អាចនឹង រក្សាសន្តិសុខ ក្នុងតំបន់កលយុទ្ធ ក្រោមការទទួលខុសត្រូវ នៃកង ទ័ពអាមេរិកាំង ហើយ អាចឲលទ្ធភាពដល់ កងទ័ពវៀតណាមខាងត្បូង ពង្រិច នូវការការពារ ប្រជាជនស៊ីវីល ឲបានមាំទាំ។

អន្តរាគមន៍ អាមេរិកាំង នៅវៀតណាមខាងត្បូង នាំរំខានដល់យុទ្ធសាស្ត្រ របស់ យួនកុម្មុយ និស្ត ដែល តម្រូវ ឲពួកនេះ យកទឹកដី កម្ពុជា ជាទឹកដីទំនុកបម្រុង ដល់សង្គ្រាមរបស់ខ្លួន សំរាប់តទល់នឹង យុទ្ធសាស្ត្រអាមេរិកាំង។ ពួកយួនកុម្មុយនិស្ត ត្រូវការ ការសមគំនិត ពីសម្តេច សីហនុ សំរាប់បំរើយុទ្ធសាស្ត្រថ្មីរបស់ខ្លួន ដើម្បី ការរស់រានមានជីវិត នៃរណសិរ្ស រំដោះជាតិនៅវៀតណាមខាងត្បូង (វៀតកុង)។ រណសិរ្សនេះ ផ្សំឡើង ដោយ ក្រុមកុម្មុយនិស្ត ជាមួយនឹង ក្រុម អ្នកជាតិនិយម និង ពួកជាតិពន្ធ រស់នៅក្នុងតំបន់ភ្នំខ្ពស់រាប។ រណសិរ្សនេះ បង្កើតឡើង នៅ ថ្ងៃទី២០ ធ្នូ ឆ្នាំ ១៩៦០ ដែលមានប្រធានទី១ គឺ លោក Nguyen Huo Tho។

ការរំលឹកជាប្រវត្តិសាស្ត្រខាងក្រោមនេះ មានគោលបំណងឲអ្នកអានយល់ស្រួល អំពីស្ថានការណ៍ នៃរឿងហេតុ ដែលមានកើតឡើង នៅភូមិសំឡូត នៅក្នុងខេត្តបាត់តំបង។

អ្នកណាក៏គេដឹងដែរថា សម្តេច សីហនុ មានការជាប់ទាក់ទងយ៉ាងខ្លាំង នៅក្នុងយុទ្ធសាស្ត្រ យួនកុម្មុនិស្តនេះ។ ការចូលដៃ របស់ព្រះអង្គ កើតចេញជា កិច្ចព្រមព្រៀងមួយ ជាមួយ ពួកវៀតកុង តាមការស្នើរពីមិត្រសំឡាញ់ របស់ព្រះអង្គ គឺ លោក Phan Van Dong, រដ្ឋមន្ត្រី ទី១ នៃវៀតណាមខាងជើង។ ក្នុងកិច្ចព្រមព្រៀងនេះ សម្តេច សីហនុ បានអនុញ្ញាត ឲកងទ័ពវៀតកុង ប្រើប្រាសទឹកដីខ្មែរ ជាមូលដ្ឋាន សេដ្ឋកិច្ច, យោធា និង សម្ភារៈកងទ័ព ដោយយកកំពង់ផែនៅ

ខេត្តកំពង់សោម ជា ឃ្លាំងទុក សម្ភារៈយោធា ដឹកចូលស្រុកខ្មែរ តាមផ្លូវសមុទ្រពីប្រទេសអ៊ឺរុប ខាងកើត។ មិនតែប៉ុណ្ណោះ យួនកុម្មុយនិស្ត យកអង្ករខ្មែរ សំរាប់ចិញ្ចឹមទាហ៊ាន របស់ខ្លួន ដែលពួកគេគ្មានការលំបាកនឹងរកបាននោះឡើយ។ គឺនៅក្នុងទឹកដីខ្មែរនេះឯង ដែលពួកកុម្មុយនិស្តយួនរៀបចំផែនការ វាយលុកដ៏ធំមួយ នៅវៀតណាមខាងត្បូង ក្នុងកំឡុងឆ្នាំ១៩៦៦និង ១៩៦៧ គ្រងនឹងធ្វើឡើង នាខែ កុម្ភៈ ឆ្នាំ ១៩៦៨។ ដូច្នេះមូលដ្ឋានទ័ពវៀតកុងនៅស្រុកខ្មែរ ត្រូវដើរតួនាទីជាអ្នកឧបត្ថម គ្រប់មធ្យោបាយ ដល់កងឯកភាព ដែលធ្វើប្រតិបត្តិការសឹង នៅវៀតណាមខាងត្បូង។

នៅក្នុងឆ្នាំ ១៩៦៦ លទ្ធផលនៃការបោះឆ្នោតរើសតំណាងរាស្ត្រ នៅស្រុកខ្មែរ ជំរុញឲសីហនុ យល់ស្របតាមរដ្ឋសភា តែងតាំងលោក ឧត្តមសេនីយ លន់ នល់ ជានាយករដ្ឋមន្ត្រី។ ព្រឹត្តិការណ៏ថ្មីនេះ ជាការគំរាម ថ្មីមួយទៀត ដល់យុទ្ធសាស្ត្រយួនកុម្មុយនិស្ត ព្រោះ រាជរដ្ឋាភិបាល លោក លន់ នល់ មានទិសនយោបាយ នាំរំខានដល់កិច្ចព្រមព្រៀង សីហនុ ជាមួយ ផាន់ វ្ញាន់ ដុង។ សំរាប់អាណត្តិទី៣ នៃរដ្ឋសភា របបសង្គមរាស្ត្រនិយម សម្តេច សីហនុ មានចំណង់ បញ្ចប់ការតែងតាំង បេក្ខជន តំណាងរាស្ត្រ ដោយចលនាសង្គមរាស្ត្រនិយម ហើយប្តូរ ប្រព័ន្ធបោះឆ្នោត តែព្រះអង្គនៅតែរក្សាគោលការណ៏ នៃគណបក្សតែមួយ ក្នុងប្រព័ន្ធនយោបាយ។

កំណែទម្រង់ពីរសំខាន់ ក្នុងការសំរេចដូរប្រព័ន្ធបោះឆ្នោត ពីសំណាក់ ព្រះប្រមុខរដ្ឋ៖

១. សមាជិក ចលនាសង្គមរាស្ត្រនិយម មានសេរីភាព ចុះឈ្មោះឈរជាបេក្ខជនតំណាងរាស្ត្រសំរាប់អាណត្តិទី៣ ;

២. ប្រព័ន្ធបោះឆ្នោត ជាការបោះឆ្នោតជាសកល និង ដោយចំពោះ។

លទ្ធផលនៃការបោះឆ្នោត នាំឲ សម្តេច សីហនុ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះបេក្ខជន ជាអ្នកស្តាំនិយម ក្នុងចលនា **សង្គម** បានជាប់ឆ្នោតជាច្រើនអនេក ឯចំណែក អ្នកឆ្វេងនិយមវិញ មានតែ វរជនបីនាក់តែប៉ុណ្ណោះ គឺ លោក ខៀវ សំផន, ហ៊ូ យន់ និង ហុយ នឹម បានជាប់ឆ្នោតជាតំណាងរាស្ត្រ។

នៅថ្ងៃទី ១៨ តុលា ឆ្នាំ ១៩៦៦ ថ្ងៃបើកសម័យអង្គប្រជុំ នៃអង្គនីតិបញ្ញត្តិ ទី៣ សម្តេច សីហនុ ថ្លែងនៅក្នុងរដ្ឋសភា នៅចំពោះមុខ តំណាងរាស្ត្រថ្មីថា៖

*«ពាក្យទី១ របស់ខ្ញុំ គឺការកោតសរសើ ដ៏ស្មោះ ចំពោះ សហជីវិន តំណាងរាស្ត្រទាំងអស់ ដែលជាតំណាងពិតប្រាកដ ជ្រើសរើស ដោយប្រជារាស្ត្រ ខុសពី បុព្វជិការី សហជីវិន ក្នុងអាណត្តិមុនៗ ដែល ចលនាសង្គមយើង ជាអ្នកជ្រើសរើសបេក្ខជនជាមុន ហើយ ដាក់ជូនឲ ប្រជារាស្ត្រសំរេចយល់ព្រម តាមសម្លេងភាគច្រើន។ ដូច្នេះ ជាការកែតប្រកែងបាន នូវន័យ នៃការពង្រឹកខ្លាំងក្លា នូវសិទ្ធិ របស់សហជីវិន ដែលជនរួមជាតិយើង ជាអ្នកប្រគល់ជូនសហជីវិត»*

ជាលើកដំបូងដែរ សម្តេច សីហនុ បើកសិទ្ធិ ឲរដ្ឋសភា ជ្រើសរើស នាយករដ្ឋមន្ត្រី សំរាប់ដឹកនាំរាជរដ្ឋាភិបាល។ តាមពិត កំណែទម្រង់ របស់ ទ្រង់ គ្រាន់តែជា សិល្បៈផ្តិនភ្នែងតែប៉ុណ្ណោះ ព្រោះបន្ទាប់ពី រដ្ឋសភា ជ្រើសតាំង លោក លន់ នល់ ជានាយករដ្ឋមន្ត្រី, នៅថ្ងៃទី២៤ តុលា មួយសប្តាហ៍ ក្រោយពីរដ្ឋសភាបោះឆ្នោតប្រគល់សេដក្តីទុកចិត្តជូន លោក លន់ នល់ ឲដឹកនាំរាជរដ្ឋាភិបាល ព្រះអង្គបានប្រញាប់បង្កើត បររដ្ឋាភិបាលមួយ ដឹកនាំដោយព្រះអង្គផ្ទាល់ ដែលសមាជិកភាគច្រើនជា អ្នកឆ្វេងនិយម ដូចយ៉ាង លោក ចៅ សេង, ខៀវ សំផន ជាអាថ៌។ បររដ្ឋាភិបាល

នេះមានបេសកកម្ម សំរាប់ តាមពិនិត្តពិច័យ សកកម្មភាព រាជរដ្ឋាភិបាលថ្មី។ ទង្វើនេះឯង ដែលនាំឲមានការបះទង្គិចគ្នារវាង រាជរដ្ឋាភិបាល ជាមួយនិង កបិចិត្ត ឬ ចិត្តរបិុលរប៉ូច របស់សីហនុ ដែលជា ចរិតធម្មជាតិ របស់ព្រះអង្គ។

## រដ្ឋាភិបាលខ្មែរមួយ ដែល យួនកុម្មុយនិស្ត ចាត់ទុកជាសត្រូវ

ដូចបានជំរាបរួចមកហើយថា រដ្ឋាភិបាល លោក លន់ នល់ នាំរំខានដល់យុទ្ធសាស្ត្រ យួនកុម្មុយនិស្តជាខ្លាំង។ ហេតុនៃការបារម្ភ របស់យួនកុម្មុយនិស្ត គឺ ការរំខាន នូវការទិញអង្ករខ្មែរតាមផ្សារងងឹត ពីសំណាក់ពួកវៀតកុង មានឈ្មួញទុច្ចរិតចិន និង ក្រុមរាជវង្ស ជា **សំចោរ**[1] សំរាប់កងទ័ពខ្លួន ដែលកំពុង ធ្វើប្រតិបត្តិការសឹក នៅ វៀតណាមខាងត្បូង។ ផ្សារងងឹតនេះមានផលពិបាកដល់ជីវភាពប្រជាជន ព្រោះគ្មានលទ្ធភាពទិញអង្ករ សំរាប់ បរិភោគ ដោយសារតម្លៃអង្ករឡើងថ្លៃខ្លាំងពេក។ ឧទាហរណ៍ នៅក្នុងឆ្នាំ ១៩៦៦ ការលក់អង្ករចេញទៅក្រៅប្រទេស ជាធម្មតា មានទម្ងន់ប្រមាណ ៣០០.០០០ តោន ក្នុងមួយឆ្នាំ តែ នៅក្នុងឆ្នាំ១៩៦៦ នៅក្នុង ស្ថិតិ រដ្ឋ ឃើញមានត្រឹមតែ ១៧០.០០០តោន តែប៉ុណ្ណោះ។ គម្លាត នេះ មាននៅក្នុងផ្សារងងឹត ដែលពួកវៀតកុង គេបង្កើតឡើង ដើម្បីសេចក្តីត្រូវការ របស់កងទ័ពគេ។ ដូច្នេះ រដ្ឋាភិបាល លោក លន់ នល់ ចាត់វិធានការ ជាប្រញាប់ គឺបំបាត់ជា បន្ទាន់ នៃផ្សារងងឹតនេះ ដោយបង្កើត នៅក្នុងខែ មករា ឆ្នាំ ១៩៦៧ អង្គការជាតិប្រមូលស្រូវពីកសិករផ្ទាល់ ដោយយក ក្រុងបាត់ដំបង ជាទីស្តីការ អង្គការ ហើយ រដ្ឋមន្ត្រីនិមួយៗ ទទួលខុសត្រូវផ្ទាល់ លើខេត្តមួយ។ តែតម្លៃស្រូវ ដែលរដ្ឋាភិបាល កំរិតទិញពី កសិករមានតម្លៃ ៣ដងថោកជាង តម្លៃលក់នៅក្នុងផ្សារងងឹត ដែលមានពួក វៀតកុងជា អ្នកទិញដាច់មុខពីប្រជាកសិករខ្មែរ។ ការណ៍នេះ ដែលនាំបង្កើត នូវការមិនសប្បាយចិត្តពីសំណាក់ប្រជាកសិករ ដែលធ្លាប់លក់ស្រូវឲពួកយួនកុម្មុយនិស្ត បានតម្លៃថ្លៃលើសលប់។

ការត្រួតពិនិត្យ នៃការប្រមូលទិញស្រូវ នេះ នាំឲ ពួកយួនកុម្មុយនិស្ត មានប្រតិកម្មជាបន្ទាន់។ ពួកវាបាន ជ្រើសរើសយកភូមិសំឡូត ជាទីកន្លែងប្រឆាំងនឹង រដ្ឋាភិបាលខ្មែរ ព្រោះវាមានភ្នាក់ងារវាជាច្រើនកំពុងធ្វើប្រតិបត្តិការ ជាសំងាត់ នៅក្នុងប្រទេសថៃ ចេះនិយាយខ្មែរច្បាស់លាស់ ចេញចូលមកក្នុងស្រុកខ្មែរ តាមភូមិនេះ ដោយមានជំនួយពី ខ្មែរវៀតមិញប្រមាណ ១០នាក់ លាក់ខ្លួន នៅក្នុងតំបន់នេះ ហើយមានអនុភាពលើប្រជាកសិករ នាំគ្នាចាក់រុកឲ ប្រជាកសិករ បះបោលប្រឆាំងនឹងវិធានការ របស់រដ្ឋាភិបាលខ្មែរ។ ដូចធម្មតា សម្តេច សីហនុ តែងតែឆ្លៀតទាញយកចំណេញនយោបាយសំរាប់ព្រះអង្គ ជានិច្ចគ្រប់ ទោមនស្ស របស់ប្រជារាស្ត្រ ប្រឆាំងនឹង អាជ្ញាធរ។ ថ្ងៃទី ៦ មករា មួយខែមុនផ្ទុះ ការបះបោល ប្រដាប់អាវុធ នៃពួកវៀតកុងនិង ខ្មែរវៀតមិញ នៅភូមិសំឡូត ដោយយកប្រជាកសិករជារនាំង សម្តេចសីហនុ ក្រោយពីបានទទួលដំណឹងពីភ្នាក់ងារចិនពីគម្រងប្រតិបត្តិការនេះ ព្រះអង្គបានចាកចេញពីស្រុកខ្មែរជាប្រញាប់ទៅកាន់ប្រទេសបារាំង ដើម្បីទុកឲ ពួកកុម្មុយនិស្តយួន មានសេរីភាពបង្កើតទំនាស់ជាមួយ រដ្ឋាភិបាល លោក លន់ នល់ ដែលព្រះអង្គទុកជាសត្រូវរួម របស់ ព្រះអង្គ។

[1] សំចោរ= អ្នកចូលដៃ ; Complice។

នៅក្នុងសៀវភៅខ្មៅ របស់ ពួកខ្មែរក្រហម ចុះផ្សាយក្នុងឆ្នាំ ១៩៧៨ មានបញ្ជាក់អំពីរឿងហេតុកើតមានឡើងនៅភូមិសំឡូត ដែលពួកខ្មែរក្រហម គេទាមទារទុកស្នាដៃ របស់បក្សកុម្មុយនិស្តខ្មែរ៖

*« នៅក្នុងខែកុម្ភៈ មានផ្ទុះការបះបោលប្រដាប់អាវុធ ធ្វើឡើងដោយប្រជាកសិករ នៅក្នុងភូមិសំឡូត ដែលនាំឲពួកយួន ភិតភ័យជាខ្លាំង ហើយនាំគ្នា ប្រយុទ្ធប្រឆាំងជាទ្វេមកលើ គណបក្សកុម្មុយនិស្តខ្មែរ។ ក្រោយបន្តិចមកយួនវាឃើញស្ថានការណ៍មានការរៀបរយឡើងវិញ ពួកវាមានសេចក្តីក្រេកអរណាស់។*

គេដឹងច្បាស់ថា ស្នាដៃនេះ ជាស្នាដៃយួនកុម្មុយនិស្ត តែពួកខ្មែរក្រហម ជំនាន់នោះ ធ្វើសកម្មភាពប្រឆាំងនឹង សីហនុ ឆ្លៀតឱកាស បោះខិតប័ណ្ណ រិះគន់ សីហនុ ថាព្រះអង្គ ទៅដើរលេងសប្បាយនៅប្រទេសបារាំង លើញើស ចេញពិហត្ថកម្លាំង របស់ប្រជារាស្ត្រ។ ខិតប័ណ្ណនេះ នាំឲ សម្តេចសីហនុ ក្រោធខឹង វិលត្រឡប់មកកម្ពុជាវិញជាបន្ទាន់ នៅថ្ងៃទី៩ មិនា។ មួយថ្ងៃក្រោយ ពីវិវដ្ត ចូលមាតុភូមិវិញ គឺនៅថ្ងៃទី ១០ មីនា ព្រះអង្គ វាយប្រហារតាមសំដី តបវិញនឹង ពួកខ្មែរក្រហម មានសេចក្តីថា៖

*«សហជីវិត ឃើញច្បាស់ថា បដិវត្តន៍ ដែល ពួកសហជីវិត នាំគ្នាបំផុសឡើង ដូចមាននៅក្នុងខេត្ត កំពង់ចាម ក្តី នៅ ប៉ៃលិន ក្តី តើ ពួកសហជីវិន ចង់នាំ យើង (ប្រជារាស្ត្រខ្មែរ) ទៅដល់ទីណា ? ចំណែក ខ្ញុំវិញ ខ្ញុំមិនមែនជា អ្នកប្រតិកិរិយា ដូច្នេះ ខ្ញុំមិនចង់ ដើរត្រឡប់ថយក្រោយវិញជាដាច់ខាត, តែ ខ្ញុំចូលចិត្ត ការវិវត្តន៍ ជាង បដិវត្តន៍ ហើយ ខ្ញុំចង់បញ្ជាក់ឲច្បាស់ នៅត្រង់ចំណុចនេះថា បើទោះបីខ្ញុំមិនស្របជាមួយនឹង ពលរដ្ឋ ឆ្វេងនិយម តែយើងត្រូវចាំបាច់ មានការវិវត្តន៍ទៅខាងឆ្វេង ; ពីស្តាំ ទៅ ឆ្វេង តែមិនទៅរក កុម្មុយនិស្ត ជាដាច់ខាត»*

អ្នកតំណាង ប្រទេសចិនប្រជាមានិត ប្រញាប់ឆ្លើយនឹង កំហឹង របស់ សម្តេចសីហនុ ដោយបញ្ជាក់ថ្វាយថា ទង្វើនេះ គ្មានការចូលរួម ពី រណសេរ្សជាតិ រំដោះវៀតណាមខាងត្បូងឡើយ (វៀតកុង)។ ដើម្បីបង្ហាញ ភាពស្មោះត្រង់ របស់ ពួកអ្នកឆ្វេងនិយម ចំពោះ សម្តេចសីហនុ លោក ខៀវ សំផន ដែលមានទូតចិនប្រជាមានិត នៅពីក្រោយ បានដឹកនាំ បាតុកម្មមួយដើម្បីសំដែងស្វាមីភក្តិ ដល់ព្រះប្រមុខរដ្ឋ តែ ក៏មានការប្រកាសជាសាធារណៈ សូមឲ លោក នាយករដ្ឋមន្ត្រី លន់ នល់ លាចេញពីតំណែង នោះដែរ។

សម្តេច សីហនុ ឆ្លើយតបនឹង បាតុកម្ម នេះ តាមការកោះប្រជុំសមាជជាតិ ជាវិសាមញ្ញ ហើយនៅក្នុង សមាជនេះ ពួកខ្មែរវៀតម៉ិញ ដែលសីហនុ អញ្ជើញឲចូលរួម ឡើងថ្លែង សូមឲ រាជរដ្ឋាភិបាលខ្មែរ ប្រដាប់អាវុធ ដល់ជនជាតិយួន ដែលរស់នៅ តាមព្រំដែន ខ្មែរ/វៀណាម ដើម្បីឲអ្នកទាំងនោះ អាចមានលទ្ធភាពការពារខ្លួន ពីការលុកលុយ ពីសំណាក់កងទ័ព អាមេរិកាំង និងយួនខាងត្បូង ចូលមកក្នុងភូមិរបស់ខ្លួន។ សំដី សេរី បែបនេះ នាំឲ អ្នកចូលរួម ក្នុងសមាជាតិស្រឡាំងកាំង ហើយយល់ឃើញថា ពួកខ្មែរ វៀតម៉ិញ អាចធ្វើសំណើរ ជាសាធារណៈបែបនេះហើយនៅចំពោះមុខ សម្តេច សីហនុ គឺច្បាស់ជាមានការអនុញ្ញាត ជាមុន ពី សម្តេច ជាពុំខាន។ ក្នុងសម័យ សង្គម នយោបាយណាមួយ ដែលមាន លក្ខណៈ ចម្លែក ខ្មែរតែងទុកជា នយោបាយជាន់ខ្ពស់ របស់ សម្តេចឪ ដូច្នេះ មិនចាំបាច់ ចង់ដឹង អ្វីនោះឡើយ។ ទង្វើនេះ សួរថា សម្តេច សីហនុ

ចង់អ្វី ? តាមពិត ព្រះអង្គ ស្ថិតនៅក្នុង ការរវើយរវាយ លែងដឹងខុសត្រូវ ធ្វើអ្វីតាមតែ រាគៈនិងមានៈ ជា **អ្នកអត្តស្នេហានិយម**[2] ទុកខ្លួនជា ព្រះ នៃមនុស្សលោក។

នៅថ្ងៃទី ២៩មីនា ឆ្នាំ ១៩៦៧, សម្តេច សីហនុ បានចោទប្រកាន់ ជាសាធារណៈ ថា តំណាងរាស្ត្របីរូប មាន លោក ខៀវ សំផន, ហ៊ូ យន់ និង ហុយ នឹម ដែលជាអ្នកឆ្វេងនិយម បានចូលរួមគំនិត ក្នុង ការបះបោ ប្រដាប់អាវុធ ខ្មែរកុម្មុយនិស្ត នៅភូមិសំឡូត។ កលយុទ្ធនេះ គឺចង់លាក់បាំងខ្មោចដំរី យកស្លឹកឈូកមួយសន្លឹកបិទ ប្រជារាស្ត្រខ្មែរ អំពី វត្តមានយួនកុម្មុយនិស្ត នៅសំឡូត ដែលជា អ្នកដឹកនាំប្រជាកសិករខ្មែរឲបះបោប្រឆាំងនឹង រាជរដ្ឋភិបាល ដឹកនាំដោយលោក លន់ នល់ ហើយដើម្បី បង្ហាញដល់សហគមន៍ អន្តរជាតិ និង ប្រជាជាតិខ្មែរ ថា រឿងហេតុកើតមានឡើងនៅសំឡូត ជា បញ្ហា ខ្មែរនិងខ្មែរ គ្មានមានយួនកុម្មុយនិស្ត លូកដៃនោះឡើយ។ នៅថ្ងៃទី ២៤ មេសា លោក ខៀវ សំផន និង ហ៊ូ យន់ ដោយមានជំណួយពីម្នាក់ងារ ទូតចិនកុម្មុយនិស្ត បានរត់គេចរួច ពីការឃុំខ្លួនក្នុងផ្ទះ ហើយនាំគ្នារត់ចូលព្រៃ ចូលរួមធ្វើសកកម្មភាព ជាមួយគណបក្សកុម្មុយនិស្តខ្មែរ។ នៅក្នុងខែ មេសា នោះដែរ នៅពេលធ្វើបេសកកម្មត្រួតពិនិត្យនៅខេត្ត កោះកុង លោក លន់ នល់ មានគ្រោះថ្នាក់រថយន្ត (ក្រឡាប់ឡាន) ដែលមាន លោក ឧត្តមសេនីយ ញឹក ជូឡុង ជាអ្នកបើកបរ។ នៅក្នុងរថយន្ត Jeep នោះ មានមនុស្សបីនាក់៖ លោក លន់ នល់ ជានាយករដ្ឋមន្ត្រី លោក ញឹក ជូឡុង ជា អគ្គនាយសេនាជាន់ខ្ពស់ នៃកងទ័ពខេមរភូមិន្ទ និង លោក ឧប គឹមអាង ជារដ្ឋមន្ត្រី ក្រសួងការពារជាតិ។ ក្នុង គ្រោះថ្នាក់នេះ មានតែ លោក លន់ នល់ ម្នាក់គត់ មានរបួសជាទម្ងន់ គឺ បាក់ជើង។ នៅថ្ងៃទី ៣០ មេសា លោក លន់ នល់ ដាក់ពាក្យថ្វាយ សម្តេច សីហនុ សូមលាលែងពីតំណែង នាយករដ្ឋមន្ត្រី ដោយលើកហេតុផល មានបញ្ហាសុខភាព។ ការលាលែងនេះ ធ្វើឲសម្តេចសីហនុស្បើយក្នុងចិត្ត ទុកជាលាភបង្កើត ជាបន្ទាន់ រដ្ឋាភិបាលពិសេស ដឹកនាំដោយព្រះអង្គផ្ទាល់។ នៅក្នុងកំឡុង ខែ ឧសភា និង មិថុនាឆ្នាំ ១៩៦៧, សម្តេច សីហនុ ក្នុង ឋានៈ ព្រះអង្គជានាយករដ្ឋមន្ត្រី បានបញ្ជា ឲកងទ័ពអាកាសខ្មែរ ទំលាក់គ្រាប់បែង លើ ភូមិ បឹងឃ្មុំ, ថ្វាក់ និង រីស្សី នាំឲគ្រួរសារខ្មែរ ជាច្រើនគ្រួរ រត់ទៅពួននៅក្នុងព្រៃ ក្បែរជើងភ្នំក្រវាញ។ ព្រះអង្គបើកប្រតិបត្តិការសឹងយ៉ាងធំមួយប្រកាសវាយពួកកុម្មុយនិស្ត នៅក្នុងតំបន់បះបោល ដែលនាំឲប្រជាជនស៊ីវិលស្លាប់ជាច្រើន។ ប្រតិបត្តិការសឹងនេះ ធ្វើឡើង ក្រោយពេលដែល ព្រះអង្គដឹងច្បាស់តាមរយៈភ្នាក់ងារ ចិន ថា ពួកយួនកុម្មុយនិស្ត និង ខ្មែរវៀតម៉ិញ បានថយខ្លួន ចេញពីដំបន់នេះអស់ហើយ។ ដូច្នេះ ប្រតិបត្តការសឹងនេះ មានលក្ខណៈ ជាការផ្តន្ទាទោស ដល់ប្រជាកសិករខ្មែរ សំរាប់ទុកជាការប្រមានដល់ខ្មែរដ៏ទៃទៀត ជាង ការវាយប្រហារ ពួកកុម្មុយនិស្តយួន។ យើងដឹងថា ចិនប្រជាមានិត តែងលេងល្បែងបោកប្រាស់ សម្តេច សីហនុ ជានិច្ច។ ធ្វើជាភ្នាក់ងារជូនដំណឹងផង និងជាអ្នកនាំកោលាហល ផង ដើម្បីរកប្រយោជន៍ ឲយួនកុម្មុយនិស្ត ដែលចិន គេទុកជាបងប្អូនរួមឈាម និងរួម មនោគមវិជ្ជា របស់គេ។

បើយោងតាម ពួកកុម្មុយនិស្តខ្មែរ ឬ ខ្មែរក្រហម រឿងហេតុ កើតឡើងនៅសំឡូត មិនមែនជាការបះបោលប្រឆាំងនឹង សម្តេច សីហនុ នោះទេ គឺ ប្រឆាំងនឹង អំពើ អយុត្តិធម៌ ដែលបង្កើតដោយ ពួកមន្ត្រីរាជការ និងនាយទាហ៊ាន ជាច្រើន នាំគ្នាមកចាប់ដី បំពានលើដី របស់ប្រជាកសិករ។ អយុត្តិធម៍នេះ នាំឲពួកគាត់ក្តៅក្រហាយ នាំគ្នាបះបោលប្រឆាំងនឹង អ្នកទាំងនេះ ដើម្បី រកយុត្តិធម៌ តែប៉ុណ្ណោះ តែ សម្តេច សីហនុ ខ្វះដំណឹងពិត ជឿលើអ្នកចាក់រុក យល់ច្រឡំ

[2] អ្នកអត្តស្នេហានិយម= ស្រឡាញ់ងប់នឹងខ្លួនឯង ; Narcissiste។

បែជាទុកប្រជាកសិករ ដែលជាជនរងគ្រោះ ជាសត្រូវនឹង ព្រះអង្គទៅវិញ។ គំនិតនេះ ត្រូវបានអ្នកចេះដឹងខ្មែរ ដែលមាននិន្នាការ ជាអ្នករាជានិយម យកមកធ្វើជាការពិត ព្រោះវាស្របនឹងគំនិតខ្លួនក្នុងទ្រឹស្តី ការតស៊ូវណ្ណៈ។ គំនិតបែបនេះ គេហៅថា **គំនិតសនិទានភាព**[3] គឺ អ្វីមួយដែលមានកើតឡើង ហើយសមតាមវិចារណញ្ញាណរបស់ខ្លួន គឺទុកជាការពិតក្នុងគំនិត ដោយមិនចាំបាច់ពិចារណារកការពិតនោះឡើយ។ គេដឹកថា ចាប់ពីឆ្នាំ ១៩៦៧ យួនកុម្មុយនិស្ត តាំងទីគ្រប់តំបន់នៅស្រុកខ្មែរ ហើយមិនអនុញ្ញាតិជាដាច់ខាត ឲពួកខ្មែរក្រហម មានភ្នកគំនិត ចង់ធ្វើអ្វីដោយខ្លួនឯងនោះឡើយ ព្រោះពួកខ្មែរក្រហម ស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន១០០%។ ត្រូវដឹងថា នៅក្នុងឆ្នាំ ១៩៦៧ សមាជិក គណមជ្ឈឹម បក្សកុម្មុយនិស្តខ្មែរទាំងអស់ ឋិតនៅក្នុងខេត្ត រតនគីរី ក្នុង មូលដ្ឋានសឹករបស់យួនកុម្មុយនិស្ត។ មូលដ្ឋាន នេះ ឋិតនៅតំបន់ព្រំសាន ដែលផ្ទុយស្រឡះពីភូមិសំឡូត ស្ថិននៅទិសខាងកើតឯណោះ។ ក្រោមការត្រួតត្រាយ៉ាងលំអិតរបស់យួនកុម្មុយនិស្ត ដូច្នេះ ពួកយួនមិនអនុញ្ញាតដាច់ខាតឲគណមជ្ឈឹមនៃគណបក្សកុម្មុយនិស្តខ្មែរ មានលទ្ធភាព ធ្វើការរៀបចំការបេះបោលប្រដាប់អាវុធ ព្រោះវាខ្លាចខូចប្រយោជន៍ របស់វានៅកម្ពុជា។ រឿងហេតុកើតឡើងនៅសំឡូត ជាស្នាដៃកុម្មុយនិស្តយួនដើម្បីធ្វើឲ រាជរដ្ឋាភិបាល លោក លន់ នល់ មានអស្ថិរភាព បន្តបេសកកម្ម ប្រឆាំងនឹងប្រយោជន៍ខ្លួនដែលមាន សម្តេច សីហនុ ជាសំចោរ។

## សេចក្តសន្និដ្ឋាន

សម្តេច សីហនុ តាមទម្លាប់ព្រះអង្គ តែងតែជ្រើសរើសដំណោះស្រាយ មិនសមាមាត្រនឹងបញ្ហា។ រឿងហេតុសំឡូត ក៏ដូច បញ្ហាឯទៀតៗ ដែលព្រះអង្គយកដំណោះស្រាយមិនសមាមាត្រ យកមកដោះស្រាយព្រោះ ព្រះអង្គមានចរិត ជាជនមានចិត្តស្រាល និង អត្តានិយម បូកចូលគ្នា នាំឲព្រះអង្គមានធាតុជា ឃាដករ មិនខ្លាចសម្លាប់មនុស្ស ជាពិសេស សម្លាប់ជនរួមជាតិរបស់ព្រះអង្គ ដើម្បីបំពេញចំណងចិត្ត រិកចិត្ត របស់ខ្លួន។ ដូចជំរាបខាងលើរួចមកហើយ នៅពេលភ្នាក់ងារចិនប្រជាមានិត ថ្វាយដំណឹង ថា យួនកុម្មុយនិស្ត និង ខ្មែរវៀតម៉ិញ ដកខ្លួនចេញអស់ ពីសំឡូត ព្រះអង្គបញ្ជាឲកងទ័ពខេមរភូមិន្ទ តាមសម្លាប់ តាមការ ទំលាក់គ្រាប់បែកដោយយន្តហោះក្តី តាមការវាយប្រហារតាមកងទ័ពជើងគោកក្តី ទៅលើប្រជាជនស្លូតត្រង់ នាំឲស្លាប់រាប់រយនាក់។ រឿងហេតុនៅសំឡូត ជាអំពើ ប្រល័យពូជសាសន៍ របស់ សម្តេចសីហនុ ដើម្បីបង្ហាញដល់ប្រជាជាតិខ្មែរថា ព្រះមិនញញើតសម្លាប់ខ្មែរ ណាមួយ ដែលប្រឆាំងនឹងព្រះអង្គ ដូចក្រោយមកទៀត នៅក្នុងឆ្នាំ១៩៧០ អនុញ្ញាតឲពួកយួនកុម្មុយនិស្ត ឈ្លានពានកម្ពុជាកាប់សម្លាប់ខ្មែរដើម្បីដណ្តើមអំណាចមកវិញ ហើយចូលដៃជាមួយនឹងពួកខ្មែរក្រហម ប្រព្រឹត្តអំពើ ប្រល័យពូជសាសន៏ខ្មែរអស់ចំនួនប្រមាណ ពីរលាននាក់ ក្នុងគោលបំណងសងសឹកប្រជាពលរដ្ឋខ្មែរ តែប៉ុណ្ណោះ។ សំនួរ របស់ សម្តេច សីហនុ ដល់ អ្នកឆ្វេងនិយមខ្មែរថា តើគោលដៅបដិវត្តន៏ របស់ សហជាវិន គឺចង់នាំ ប្រជាជនខ្មែរ ទៅដល់ទីណា ? សពសីហនុខ្លួនឯង បានឆ្លើយនឹងសំណួរនេះ តាំងតែពីដើមទីមក គឺព្រះអង្គ ចូលធ្វើសហការជាមួយពួកកុម្មុយនិស្តដឹកនាំប្រជាពលរដ្ឋខ្មែរ ឲចូលក្នុងទ្រុងកុម្មុយនិស្តយួន ធ្លាក់ខ្លួនជា ជាប្រជាជនអាណានិគមយួនសព្វថ្ងៃនេះ។ ៚

[3] គំនិតសនិទានភាព= ភាពសមតាមវិចារណញ្ញាណ ; rationalité de pensée។